# ការដាំត្រកួន

## ១. លក្ខណៈទូទៅរបស់ត្រកួន

ត្រកួនជារុក្ខជាតិត្រូវការពន្លឺថ្ងៃ និងទឹកគ្រប់គ្រាន់។ វាអាចដុះលូតលាស់លើដីគ្រប់ប្រភេទ ជាពិសេសដីល្បាយខ្សាច់ដែលមានជីជាតិ។ យើងអាចដាំវាបានគ្រប់រដូវទាំងនៅលើដី និងក្នុងទឹក។

**តើមានហេតុផលល្អៗអ្វីខ្លះដែលនាំឲ្យយើងដាំត្រកួន?**

១- មានជីវជាតិច្រើនសម្រាប់ចិញ្ចឹមរាងកាយ

២- ងាយស្រួលដាំថែទាំ និងងាយស្រួលលក់នៅទីផ្សារ

៣-ឆាប់បានប្រមូលផល និងប្រមូលផលបានច្រើនដង

៤- អាចដាំដុះបានលើផ្ទៃដីគ្រប់ប្រភេទ និងគ្រប់រដូវឲ្យតែមានទឹកគ្រប់គ្រាន់

៥- ដើម ស្លឹកយកទៅធ្វើម្ហូបបានច្រើនមុខ និងមានរសជាតិឆ្ងាញ់សម្រាប់មនុស្ស និងអាចធ្វើជាចំណីសត្វ (ជ្រូកមាន់)។

៦- ងាយស្រួលក្នុងការថែរក្សាទុកគ្រាប់ពូជ។

**តើត្រកួនមានសារធាតុអ្វីខ្លះ?**

**វីតាមីនសេ** : ជួយរក្សាធ្មេញ និងអញ្ចាញធ្មេញឲ្យមានសុខភាពល្អ ។ បង្កើនសមត្ថភាពទប់ទល់ ឬភាពស៊ាំនឹងជម្ងឺផ្សេងៗ

**វីតាមីនបេ** : ជួយឲ្យសរសៃប្រសាទដំណើរការ និងបង្កើនការរំលាយអាហារ។

**វីតាមីនអា** : ជួយឲ្យភ្នែកភ្លឺមើលឃើញបានច្បាស់ល្អ។

**ជាតិដែក** : ជួយក្នុងការបង្កើតគ្រាប់ឈាមក្រហម ជាពិសេសស្ត្រីមានផ្ទៃពោះត្រូវញ៉ាំត្រកួនឲ្យបានច្រើន។

**ប្រូតេអ៊ីន** : ជួយដល់ការលូតលាស់ខាងរាងកាយជាពិសេសសាច់ដុំ។

**កាល់ស្យូម** : ជាសារធាតុរ៉ែសម្រាប់ជួយឲ្យឆ្អឹង និងធ្មេញរឹងមាំ ។

## ២. ការរៀបចំរងត្រកួន

ចង់ឲ្យត្រកួនដុះលូតលាស់បានល្អ យើងត្រូវរើសទីកន្លែងដាំ និងធ្វើរងឲ្យបានត្រឹមត្រូវស្របតាមរដូវនីមួយៗ។

## ៣. ការជ្រើសរើសទីកន្លែងដាំ

ការជ្រើសរើសទីកន្លែងដាំជាការសំខាន់បំផុតដើម្បីជៀសផុតពីការខូចខាត និងដើម្បីទទួលផលបានច្រើន។

**រដូវប្រាំង** : ជ្រើសរើសទីកន្លែងដាំជិតប្រភពទឹក ដើម្បីងាយស្រួលក្នុងកាស្រោចស្រព។

**រដូវវស្សា** : ជ្រើសរើសទីកន្លែងដាំនៅលើដីទួលខ្ពស់មិនលិចទឹក ។

***អ្នកជាំគួរដឹង*** : *ត្រកួនគោកអាចដាំបានគ្រប់រដូវឲ្យតែដីធ្លាមានជីជាតិ និងមានទឹកគ្រប់គ្រាន់។*

## ៤.ការធ្វើរងដាំ

- ឧបករណ៍រៀបចំដី និងជីទ្រាប់បាតរង - ចបជីក ចបកាប់ - រនាស់ដៃ បង្គី

- ខ្សែម៉ែត្រ - បង្គោលចុងស្រួច - ជីកំប៉ុស្ត ជីលាមកសត្វ






### ៤.១. ការធ្វើរងដាំនៅរដូវវស្សា

១- កាប់ដីហាលរយៈពេល១០ថ្ងៃ ទុកឲ្យស្ងួត ទើបវាយបំបែកដីឲ្យម៉ដ្ឋ ។

២- លើករងត្រកួនដែលមានទទឹង១ម៉ែត្រកំពស់១តឹកកន្លះទៅ២តឹក ឯបណ្តោយអាស្រ័យទៅតាមស្ថានភាពដីវែង ឬខ្លី។

**ហេតុអ្វីត្រូវលើករងឲ្យខ្ពស់នៅរដូវវស្សា?**

ដើម្បីការពារទឹកដក់ ឬលិចរង ពេលមានភ្លៀងធ្លាក់ជោកជាំ ។

### ៤.២. ការធ្វើរងដាំនៅរដូវប្រាំង

១- កាប់ដីហាលតែរយៈពេល ១អាទិត្យ បន្ទាប់មកវាយបំបែកដីឲ្យម៉ដ្ឋ។

២- លើករងដាំដែលមានទទឹង ១ម៉ែត្រ កំពស់១តឹក និងបណ្តោយអាស្រ័យទៅតាមស្ថានភាពដីវែង ឬខ្លី។

## ៥. ការដាក់ជីទ្រាប់បាត

១- យកជីកំប៉ុស្ត ឬជីលាមកសត្វផ្សេងៗ ដែលពុកផុយមករោយពីលើរង។

២- យកចបកាប់មកជ្រំៗដីត្រឡប់សារចុះសារឡើង ដើម្បីឲ្យជីចូលទៅក្នុងដី។

៣- យករនាស់ដៃមករាស់ដីឲ្យបានស្មើល្អ ។

**<u>អ្នកជាំគួរដឹង</u>**

- *ត្រូវរោយជីកំប៉ុស្ត ឬជីអាចម៍គោដែលពុកផុយ ចំនួនពី ៣ ទៅ៥គីឡូ នៅលើដីមួយម៉ែត្រប្អូនជ្រុង ។*

- *មិនត្រូវយកជីកំប៉ុស្តទៅចាក់គរទុកចោលនៅលើរង ដោយមិនជ្រំត្រឡប់នោះទេ ព្រោះវាធ្វើឲ្យសារជាតុចិញ្ចឹមនៅក្នុងជីហើរទៅតាមខ្យល់។*

ដើម្បីឲ្យគ្រាប់ពូជដុះបានល្អ យើងត្រូវយកគ្រាប់ពូជណាដែលគ្មានជម្ងឺ គ្មានការបំផ្លាញពីសត្វល្អិត និងមិនទុកយូរឆ្នាំ។

## ៦. ការរៀបចំគ្រាប់ពូជ

### សម្ភារៈសម្រាប់បណ្ដុះ និងវត្ថុធាតុដើមសម្រាប់ដាំ

កូនឈើសម្រាប់ឆូតរងដាំ ចង្អេរ ចានដែក ក្រណាត់សម្រាប់ខ្ចប់គ្រាប់ពូជត្រកួន កំទេចចំបើង។



កូនឈើសំរាប់ឆូតរងដាំ ចង្អេរ ចានដែក





## ៧. របៀបបណ្ដុះ

១- យកគ្រាប់ពូជមកអុំរោយ និងរើសកំទេចកំទីសំរាមចោល។

២- ដាក់គ្រាប់ពូជសំដិលហាលថ្ងៃស្រទន់រយៈពេល ១ទៅ២ម៉ោង ដើម្បីសម្លាប់មេរោគដែលនៅជាប់នឹងគ្រាប់។

៣- ត្រាំគ្រាប់ពូជក្នុងទឹករយៈពេល ១២ម៉ោង (១យប់)។

៤- ស្រង់គ្រាប់ពូជ រួចយកក្រណាត់មកខ្ចប់ និងស្រោចទឹកឲ្យសើមៗជានិច្ច។ ផ្អាប់ទុកពី ១ទៅ២យប់ ដើម្បីឲ្យគ្រាប់ដុះពន្លកទើបយកទៅដាំ ។





**អ្នកដាំគួរដឹង**

*ត្រូវហាលគ្រាប់ពូជនៅពេលថ្ងៃស្រទន់ គឺចន្លោះពីម៉ោង៨ ដល់ម៉ោង១១ព្រឹក ។ ហាលគ្រាប់ពូជនៅក្រោមថ្ងៃក្ដៅខ្លាំងធ្វើឲ្យគ្រាប់ពូជឆ្អិនពេក ជាហេតុនាំឲ្យគ្រាប់មិនដុះ។*

## ៨. ការសាបគ្រាប់ ឬការដាំ

ឆូតកូនចង្អូរកាត់ទទឹងរងជំរៅ១សង់ទីម៉ែត្រនៅរដូវប្រាំង និង២សង់ទីម៉ែត្រនៅរដូវវស្សា ។

របៀបដាំ

១- ឆូតរងដាំដោយទុកចន្លោះពីចង្អូរមួយទៅចង្អូរមួយចម្ងាយកន្លះតឹក នៅរដូវប្រាំង និង១តឹកនៅរដូវវស្សា។

២- ពាយគ្រាប់ដោយទុកចន្លោះពីគ្រាប់១ទៅ១ ប្រវែងមួយសង់ទីម៉ែត្រ នៅរដូវប្រាំង និងប្រវែង ២សង់ទីម៉ែត្រ នៅរដូវវស្សា។





**អ្នកដាំគួរដឹង**

*ពាយគ្រាប់តាមកូនចង្អូរឲ្យស្មើល្អ។ នៅលើផ្ទៃដីមួយម៉ែត្របួនជ្រុងត្រូវប្រើគ្រាប់អស់ចំនួន ៥ក្រាម។ ក្រោយពីពាយគ្រាប់ត្រកួនរួច ត្រូវយកកំទេចចំបើង ឬកំទេចស្លឹកឈើគ្របពីលើដើម្បីការពារកុំឲ្យហួតសំណើម ។*

## ៩. ការថែទាំមុនពេលប្រមូលផល

ដំណាំត្រកួនមិនពិបាកថែទាំទេ គឺយើងគ្រាន់តែដកស្មៅ ស្រោចដី និងស្រោចទឹកឲ្យបានគ្រប់គ្រាន់ ប៉ុណ្ណោះ។

## ១០. ការស្រោចទឹក និងការធ្វើស្មៅ

ដំណាំត្រកួនត្រូវការទឹកច្រើន។ ប្រសិនបើខ្វះទឹក ដើមត្រកួនលូតលាស់មិនបានល្អទេ វាក្រិន ឬរឹង ។

- នៅរដូវប្រាំងក្រោយពីដាំហើយ យើងត្រូវស្រោចទឹកឲ្យជោកមួយថ្ងៃ ២ដង (ព្រឹក និងល្ងាច)។
- ជ្រំដី និងដកស្មៅជុំវិញគល់ត្រកួនឲ្យបានញឹកញាប់ក្រោយពីត្រកួនដុះបានរយៈពេលពី ៤ ទៅ ៥ថ្ងៃ ព្រោះក្នុងរយៈពេលនេះស្មៅកំពុងដុះលូតលាស់ប្រជែងជាមួយត្រកួនដែរ ។

**អ្នកដាំគួរដឹង**

*នៅរដូវវស្សាយើងមិនបាច់ស្រោចទឹកទេ។ ប្រសិនបើមានភ្លៀងដក់ទឹកច្រើន ត្រូវបង្ហូរទឹកចេញពីរង។ ការជ្រំដី និងការធ្វើស្មៅធ្វើឲ្យដីធូរងាយជ្រាបទឹក ខ្យល់ចេញចូលបានស្រួល និងធ្វើឲ្យត្រកួនដុះបានល្អ ហើយមានដើមធំខ្លី។*

## ១១. ការធ្វើជីទឹក និងការស្រោចជីទឹក

ត្រកួនក៏ដូចជាដំណាំផ្សេងទៀតដែរ ដែលត្រូវការជីសម្រាប់បំប៉នបន្ថែម ដើម្បីឲ្យកាន់តែដុះលូតលាស់ល្អ។

**ឧបករណ៍និងវត្ថុធាតុដើមសម្រាប់ធ្វើជីទឹក**

- ពាងសម្រាប់ត្រាំជី -ឫស្សី ឬឈើសម្រាប់កូរជី -ក្បាលពោះវៀន និងអាចម៍កង្កែប ១គីឡូ
- ខ្យង១គីឡូ -ខ្ទៅ១គីឡូ -សំបកក្តាម១គីឡូ -សំបកខ្នុរ -សំបកល្ហុង -អាចម៍មាន់០,៥គីឡូ -អាចម៍ប្រចៀវ ០,៥គីឡូ
- ទឹក -ស្ករត្នោតឬទឹកស្ករអង្គ -ស្លឹកអង្កាញ់